# ការសម្ភាសរបស់លោកពូ ភឿន សេង

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ភឿន សេង

កៈ ចាស សូមជំរាបសួរលោកពូ ចាសខ្ញុំឈ្មោះហេង សុខជីវី ខ្ញុំកមពីខាងក្រុមការងារ ហើយលោកពូសុខសប្បាយអត់ថ្ងៃនេះលោកពូ?

ខៈ បាទ

កៈ ចាស លោកពូមានឈ្មោះអ្វីដែរលោកពូ?

ខៈ ខ្ញុំឈ្មោះ ភឿន សេង

កៈ ឈ្មោះនេះត្រូវជាមួយអត្តសញ្ញាប័ណ្ណ?

ខៈ បាទ ត្រូវជាមួយអត្តសញ្ញាប័ណ្ណ

កៈ លោក ពូភឿន រ៉េង?

ខៈ ភឿន សេង

កៈ លោក ពូភឿន សេង? ចាស សុំទោសលោកពូ ភឿន សេង។

ខៈ នឹង

កៈ លោកពូ ភឿន សេងហើយសព្វថ្ងៃលោកពូនៅភូមិ ឃុំ នៅខេត្តណាដែល?

ខៈ ទីលំនៅបច្ចុប្បន្ននៅទីនេះ។

កៈ សូមបញ្ជាក់បន្តិចមក លោកពូ។

ខៈ ភូមិ ស្ទឹងស្រូវ ឃុំ ស្ទឹង...ខេត្ត តាខ្មៅ។

កៈ ហើយសព្វថ្ងៃលោកពូមានអាយុប៉ុន្មានហើយ?

ខៈ អាយុ៥៣ហើយ។

ក៖ លោកពូកើតខែ ថ្ងៃ ឆ្នាំណាដែរលោកពូចាំអត់?

ខ៖ ខ្ញុំកើតនៅឆ្នាំ១៩៦៥

ក៖ ខែ?

ខ៖ ខែ ខែ៩

ក៖ ហើយថ្ងៃលោកពូណា?

ខ៖ ថ្ងៃចន្ទ័

ក៖ ថ្ងៃចន្ទ័ ហើយលោកពូឥឡូវលោកពូមានក្រុមគ្រួសារហើយលោកពូរៀបការហើយ?

ខ៖ បាទ

ក៖ ហើយអ៊ុំស្រី ត្រូវជាប្រពន្ធរបស់លោកពូគាត់នៅជាមួយគ្នា ក្រុមគ្រួសារគាត់នៅជាមួយគ្នាម៉ង់?

ខ៖ បាទ

ក៖ ហើយសព្វថ្ងៃលោកពូមានកូនប៉ុន្មាននាក់ដែរ?

ខ៖ កូន៧នាក់

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ខ៖ ស្រី២ ប្រុស៥

ក៖ ប្រុសច្រើនជាងស្រី

ខ៖ បាទ

ក៖ ហើយពួកគាត់បានរៀនទាំងអស់គ្នាតើ?

ខ៖ ពួកគាត់ឈប់រៀនអស់ហើយ

ក៖ គាត់ថ្នាក់ទីប៉ុន្មានហើយបានឈប់រៀន?

ខ៖ គាត់ឈប់រៀនកាលថ្នាក់ទី៧ហើយនៅផ្ទះ។

ក៖ ហើយបងៗគាត់រៀបការហើយឬនៅ លោកពូរៀបកូនបានប៉ុន្មាននាក់ហើយ?

ខ៖ រៀបការកូនបាន៥នាក់ហើយ។

ក៖ អូ លោកពូរៀបការកូនបាន៥នាក់ហើយ ដូច្នោះនៅតែ២នាក់ក្រោយទេ ចាស ហើយលោកពូចាំឈ្មោះកូនម្នាក់ៗទាំង៧នាក់នឹងទេ?

ខ៖ បាទ ចាំតើមីបងមានកូនបាន២សុទ្ធតែស្រីៗ ហើយបន្ទាប់ទៀតកូន១ ហើយបន្ទាប់មកទៀតកូន១ដែរ បន្ទប់មកទៀតមិនទាន់មានកូនទេទឹមតែការ។

ក៖ ចុះ ឈ្មោះពួកគាត់លោកពូ ចាំអត់?

ខ៖ ចាំតើ ឈ្មោះ សេង សំណាង សេងផានីត សេង បញ្ញា សេង សំណាន សេង គន្ធា សេង មករា សេង ផារី។

ក៖ លោក ពូចាំបានល្អមែនទែនទាំងកូនទាំង៧ ចាសសុទ្ធតែកូនសំណាបហើយ។

ខ៖ បាទហាហា

ក៖ ហើយលោកពូ ដោយសារកូនទាំង៧គាត់ការអស់ហើយតែនៅសល់កូន២ស្រីមួយ ប្រុសមួយត្រូវអត់លោកពូ ចឹងលោកពូមិនសូវខ្វារខ្វល់ប៉ុន្មានទេ?

ខ៖ បាទ

ក៖ ចាសចុះ លោកពូនៅមានគំរោងការយ៉ាងណាដែលសំរាប់កូននៅខាងក្រោយទៀត?

ខ៖ គំរោងការម៉េច ឥឡូវ

……

ក៖ គេមករកស៊ីម៉ង់លោកពូ?

ខ៖ បាទ

ក៖ ចឹងខ្ញុំសូមសួរតពីមុនសំរាប់កូនទាំងពីរនាក់ដែរមិនទាន់បានការ?

ខ៖ សំរាប់កូនដែរមិនទាន់បានការចង់អោយវាធ្វើការ

ក៖ ហើយសំរាប់ផ្ទះវិញលោកពូ?

ខ៖ ហាហា មិនទាន់ដឹងបានកូនណាកូននៃទេ។

ក៖ ផ្ទះនេះជារបស់លោកពូផ្ទាល់?

ខ៖ បាទ

ក៖ ចុះកសាងនៅក្នុងឆ្នាំណាដែល?

ខ៖ ទឹមតែធ្វើក្នុងកំឡុងប្រហែលបាន៥ឆ្នាំ

ក៖ លោកពូ ធ្វើខ្លួនឯង?

ខ៖ បាទ

ក៖ អូស្អាតមែន ចុះរចនាលោកពូយកពីណាមក?

ខ៖ មើលផ្ទះ គេហើយប្រាប់ជាដូចថានឹង។

ក៖ ចាស លោកពូថាធ្វើចឹងស្អាតលោកពូធ្វើទៅ?

ខ៖ បាទ

ក៖ ចុះ អស់ប៉ុន្មានដែរលោកពូ?

ខ៖ តឹងអស់សរុបអស់៧០០០$ ។

ក៖ តឹងអស់អស់៧០០០$ សរុបទាំងក្រាលអី ណោះលោកពូ?

ខ៖ បាទ

ក៖ ខ្ញុំស្មាគតែលោកពូ ធ្វើផ្ទះនេះខ្លួនឯង?

ខ៖ អត់ទេ ខ្ញុំពិការ ខ្ញុំចេះធ្វើដៃរនឹងតែតាំងពីពិការមកអត់។

ក៖ លោកពូពិការប៉ុន្មានឆ្នាំហើយ?

ខ៖ តាំងពីមុនធ្វើផ្ទះនេះម្លេះ

ក៖ ហ៎ ឥឡូវបានធូរហើយនៅលោកពូ?

ខ៖ ឥឡូវបានតែដើរនៅក្បែរៗផ្ទះនឹងធ្វើការអីអត់កើតទេ។

ក៖ វាចេះតែយ៉ាងម៉េចដែរលោកពូ?

ខ៖ វាចេះតែរឹងដៃរឹងជើង។

ក៖ ហ៎ លោកពូទៅពេទ្យគេអោយថ្នាំមកលោកពូមក?
ខ៖ បាទ

ក៖ ហើយគាត់មានណាត់លោកពូទៅទៀតទេ?

ខ៖ អត់តឹងពីទៅពេទ្យកូរ៉េ មក អត់មានណាត់ទៀតផង។

ក៖ ចាស ជូនពរអោយលោកពូបានឆាប់ជាង សាសស្បើយពីជំងឺចាស

ខ៖ បាទ

ក៖ ចុះលោកពូមានចាំពីឪពុកម្ដាយលោកពូទេ?

ខ៖ ចាំ

ក៖ ចុះគាត់មានឈ្មោះអ្វីដែរលោកពូ?
ខ៖ ម្ដាយខ្ញុំគាត់ឈ្មោះ តាំង ហួយ ឪពុកខ្ញុំឈ្មោះប៉ោ ហឿន។

ក៖ ឥឡូវតើគាត់នៅមានជីវិតទេលោកពូ?

ខ៖ គាត់ខូចយូរហើយ តាំងពីដាច់ហើយ

ក៖ តើគាត់ខូចដោយសារអ្វីដែរលោកពូ?

ខ៖ ឪពុកខ្ញុំគាត់ ចាស់ជរា ហើយម្ដាយខ្ញុំគាត់ឈឺតិចតួច នឹងគួបផ្សំនឹងជំងឺចាសជរាផង។

ក៖ ចាស ហើយចាសលោកពូ ចុះគាត់មានទីលំនៅនៅទីនេះដែរឬក៏?

ខ៖ អត់ទេ គាត់នៅស្រុកនោះ

ក៖ នៅភូមិ ឃុំ ខេត្តណា?

ខ៖ នៅស្រុកស្អាង ខេត្តកណ្ដាល។

ក៖ តាំងពីរនាក់តែម្ដង?

ខ៖ បាទ

ក៖ ចុះ លោកពូមានចាំគាត់មានកូនប៉ុន្មាននាក់ត្រូវជាបងប្អូនលោកពូ?

ខ៖ ខ្ញុំមាន៤នាក់

ក៖ លោកពូកូនទីប៉ុន្មាន?

ខ៖ ខ្ញុំកូនទី២

ក៖ ពួកគាត់នៅមានជីវិតតើលោកពូបងប្អូនលោកពូ?

ខ៖ បាទ

ក៖ ល្អមែនទែន ហើយចុះលោកពូគាត់មានឧស្សាហ៍មក លេង លោកពូអត់?

ខ៖ បានទៅលេងគ្នាតើ ម្ដងៗ។

ក៖ ចាស ពួកគាត់នៅខេត្តណាដែលលោកពូ?

ខ៖ នៅស្រុកកំណើតនេះ នៅស្រុកស្អាងនឹង។

ក៖ ទាំង៤នាក់ម៉ង់?

ខ៖ បាទ៣នាក់ នៅនឹងបែកតែខ្ញុំមកនេះមួយ។

កៈ ហើយពួកគាត់បីនាក់នៅជាមួយគ្នា?

ខៈ បាទនៅនឹងជាមួយគ្នា

កៈ ហឹស ចាស ហើយកាលនឹងលោកពូមាននៅចាំជំនាន់អាពតទេ?

ខៈ បាទ

កៈ កាលនឹងគេជំលាស់លោកពូទៅណា?

ខៈ គេអោយទៅធ្វើទំនុបផ្លូវបើកឡាន ជីកបន្លាយ ខ្វាតខ្វែង នៅស្រុកស្អាងនឹង ហើយផ្លូវនៅស្រុកស្អាងនឹងចាក់ទៅតាព្រហ្ម ទៅបឹងខ្វាង បឹងទូល តាមស្ទឹងអីនឹងហាហ។

កៈ ហឹស ចុះកាលនឹងលោកពូធ្វើការហត់ទេ?

ខៈ គេអត់សូវអោយបាយហូបទេ ជិតដាមដល់ឥឡូវ។

កៈ ហ៎ កាលនឹងពិបាកខ្លាំងណាស់ណាលោកពូ?

ខៈ ហ៎ វាពិបាកខ្លាំងណាស់ ហើយតឹងណាស់

កៈ តឹងនឹងគេមានធ្វើបានលោកពូអត់? គេមានវ៉ៃលោកពូអត់?

ខៈ អានឹងបើយើងធ្វើតាមគេអត់អីទេ។ គេធ្វើ ធ្វើទៅដល់ពេលសំរាកក៏សំរាកជាមួយគេទៅ។

កៈ ហើយលោកពូគេអោយធ្វើការប៉ុន្មានម៉ោងដែរ?

ខៈ ចាប់ពីម៉ោង៦ព្រឹករហួតដល់ម៉ោង១១ទៅ១២ បានបានបាយហូបដែរនឹងហើយពីម៉ោង៥ទៅ៦ល្ងោចដែរនឹងចឹងពេលខ្លះធ្វើដល់ម៉ោង១១ទៅ១២ យប់ទៀតនោះ។

កៈ ធ្វើដល់យប់ទៀត?

ខៈ បាទ

កៈ ហើយធ្វើការត្រូវក្រោកពីម៉ោង៨?

ខ៖ បាទ ពេលខ្លះភ្លៀង ត្រូវធ្វើតាំងភ្លៀងទៀត។

ក៖ ចុះមិនឈឺទេកាលនឹង?

ខ៖ ចេះអត់អីដែរ។

ក៖ អត់ឈឺអីទេ?

ខ៖ អត់

ក៖ ហ៎ លោកពូកាលនឹងបានបាយពិសារ គេអោយបាយ?

ខ៖ បាទ អត់ចេះឈឺអី ហើយកាលនឹងកំលាំងក៏អត់មានអនថយ។

ក៖ ចឹងកាលនឹងលោកពូបានបាយ៣ពេលកាលនឹង?

ខ៖ អត់ទេ ២ពេល។

ក៖ ២ពេល ពេលព្រឹកពេលល្ងាច?

ខ៖ ពេលថ្ងៃអត់

ក៖ អូរ

ខ៖ ពេលថ្ងៃត្រង់នឹងពេលល្ងាចនឹង។

ក៖ ចឹងពេលព្រឹកអត់វិញ។

ខ៖ បាទ

ក៖ ចេះសំណាងកាលនឹងអត់លោកពូអត់ឈឺ
លឺថាកាលនឹងបើឈឺគេយកទៅភ្ជួរទឹកដូងអត់មានសារ៉ូប ខ្ញុំលឺចឹងពិតអត់លោកពូ
តើលោកពូធ្លាប់ជួបអត់?

ខ៖ បាទ កាលនឹងអត់មានសារ៉ូមទេ គេភ្ជួរទឹកដូងមែន
អានឹងគេប៉េះពីលើដូងមកគេដាក់ក្នុងក្រមាមកហើយកាប់ដាក់ប្ញម។

កៈ ចាស
ចុះកាលនឹងលោកពូមានបានចាំអីដែលលំបាកជាងគេពីសម័យខ្មែរក្រហមនឹងអត់លោកពូ?

ខៈ ពិបាកជាងគេលើទំនុកលើប្រឡាយ វាមានតែប៉ុននឹង។

កៈ ចុះមិត្តភក្រ័កាលជំនាន់នឹងលោកពូមានចាំពួកគាត់អត់?

ខៈ មានតែវាភ្លេច អស់ហើយ ដឹងនៅឯណាទេ។

កៈ តែពួកគាត់នៅរស់រានមានជីវិតតើលោកពូ?

ខៈ អត់ដឹង

កៈ កាលជំនាន់នឹងគេជំលាស់?

ខៈ បាទ កាលនឹងជំលាស់មិនដែលនៅភូមិមូលគ្នាទេ ចឹងភូមិយើងគេមកនៅ
ហើយយើងទៅនៅភូមិឃុំគេបំបែកគ្នាអស់។

កៈ ចាស

ខៈ អត់សូវស្គាល់

កៈ ចាស ចុះ អ្នកដែលដេកជាមួយលោកពូកាលជំនាន់អាពតនឹងលោកពូមានចាំពួកគាត់ទេ?

ខៈ ចាំ

កៈ គាត់នៅមានជីវិតទេលោកពូ?

ខៈ អត់ដឹង

កៈ ចុះ លោកពូមានបានឃើញអាពតយកមនុស្សទៅសំលាប់ផ្ទាល់ភ្នែក?

ខៈ ធ្លាប់ បានមើលនៅក្នុងកន្លែងខ្ញុំពេលគេហៅទៅហើយបាត់រហូតបានទាំងយប់។

កៈ ហ៎ ចឹងលោកពូមានភ័យទេ?

ខៈ ខ្ញុំភ័យដែលនឹងបើហៅទៅបាត់ឆឹង។

កៈ ចឹងដេកលែងលក់ហើយចឹង?

ខៈ នឹង

កៈ ហាហាហា
ហ៎លោកពូកូនចៅជំនាន់ក្រោយមិនដឹងទេពេលលតែចាស់ៗអ្នកជំនាន់មុនប្រាប់ចេះតែស្តាប់ទៅ ហើយភ័យទំរាមតែគាត់កើតនៅក្នុងជំនាន់នឹងទៀត។
ចឹងកាលនឹងលោកពូចង់អោយរួចពីជំនាន់នឹងឆាប់ៗអត់?

ខៈ បាទចង់ តែមិនដឹងធ្វើយ៉ាងម៉េច?

កៈ ចឹងចេះតែចាំៗទៅ?

ខៈ បាទ

កៈ ហើយថ្ងៃដែលបានរំដោះមកលោកពូបានសប្បាយចិត្ត?

ខៈ បាទ អូនិយាយពីថ្ងៃខ្ញុំ ឈឺជើងនៅពេលរំដោះនឹង ខ្ញុំសូមពេទ្យចេញបាន ហើយឡើងវិញជើងទទើត ខ្ញុំសូមពេទ្យចេញមកពេលនោះឃើញឡានគេក៏ឡើកដៃសូមគេ គេក៏អោយជិះពេលបែក ហើយមកដល់ទីនោះក៏ចូលព្រៃហើយសូមដេកផ្ទះគេមួយយប់ ហើយបានធ្វើដំណើរទៅទៀត ។

កៈ ហើយបន្ទាប់មកបានលោកពូបានចាប់ដីនៅទីនេះហើយកសាងផ្ទះ។

ខៈ ផ្ទះនេះទិញគេទេ។

ខៈ អូ អីចឹងផ្ទះនេះទិញគេទេមិនមែនចាប់ពីផុតជំនាន់អាពតទេ?

កៈ ចុះ
ហើយលោកពូដែលហេតុការណ៍នឹងវិញចុះអ៊ុំស្រីត្រូវជាប្រពន្ធលោកពូគាត់មកជាមួយលោកពូដែរ?

ខៈ កាលនឹងខ្ញុំមិនទាន់បានរៀបការ

កៈ អូ ពូមិនទាន់រៀបការ

ខ៖ នឹងហើយ

ក៖ ពូរៀបការឆ្នាំណាលោកពូមានចាំទេ?

ខ៖ អត់ចាំឆ្នាំទេ ហាហា

ក៖ អត់ចាំ?

ខ៖ ប្រហែលជា២ឆ្នាំហើយ

ក៖ ចុះកាលនឹងលោកពូស្រលាញ់គ្នាដោយខ្លួនឯងឬឪពុកម្ដាយជាអ្នកផ្សំផ្គុំអោយ?

ខ៖ ឪពុកម្ដាយជាអ្នកផ្សំផ្គុំអោយ ។

ក៖ ចុះកាលនឹងលោកពូស្រលាញ់គាត់អត់ចឹង?

ខ៖ កាលនឹងអត់ទាន់ចេះស្រលាញ់ប្រពន្ធផង

ក៖ ហ៎

ខ៖ ម្ដាយឪពុកខ្លាចគេយកធ្វើទាហានបានជាឪពុកម្ដាយគាត់អោយយកប្រពន្ធ។

ក៖ អូកាលនឹងអ្នកមិនទាន់រៀបការគេយកធ្វើទាហាន?

ខ៖ នឹងគេយកធ្វើទាហានអស់ទៅកាលជំនាន់នឹង
អ្នកអត់យកប្រពន្ធគេយកទៅធ្វើទាហានអស់ចឹងមែននឹង។

ក៖ ចាសកាលនឹងសម័យជំនាន់ណា?

ខ៖ កាលដាច់ហើយនឹង

ក៖ កាលដាច់ហើយភ្លាមៗ?

ខ៖ បាទ

ក៖ ចុះប្រពន្ធលោកពូគាត់អាយុប៉ុន្មានហើយ?

ខ៖ ៦០អីហើយ គាត់បងខ្ញុំ២ឆ្នាំ។

ក៖ គាត់បងលោកពូ២ឆ្នាំ ហើយឥឡូវគាត់នៅតែដូចថាសុខភាពគាត់អីនៅតែរឹងមាំទេលោកពូ?

ខ៖ បាទគាត់នៅតែរឹងមាំ តែគាត់នៅតែវិលមុខឈឺក្បាល។

ក៖ ចុះគាត់អត់មានធ្វើការអ្វីទេ?

ខ៖ ឥឡូវគាត់ទៅបេះត្រកួនបាត់ហើយ។

ក៖ គាត់បេះយកទៅលក់នៅផ្សារ?

ខ៖ បាទ

ក៖ ចុះសព្វថ្ងៃក្រុមគ្រួសារលោកពូប្រកបមុខរបរអ្វីដែរ?

ខ៖ មានតែបេះត្រកួនមួយមុខនឹង។

ក៖ ចាស
ដល់ពេលចឹងរាល់ថ្ងៃលោកពូអាចចិញ្ចឹមគ្រួសារបានហើយឬក៏លោកពូគិតថាវាគ្រប់គ្រាន់ហើយ?

ខ៖ បានគ្រប់គ្រាន់ទប់ទល់

ក៖ អីចឹងតើបានទប់ទល់តែមួយថ្ងៃៗទេ?

ខ៖ បាទ

ក៖ ចុះលោកពូរំពឹងគិតថាចង់បានជំណូប៉ុន្មានសំរាប់គ្រួសារដែរ?

ខ៖ ជំណូអោយតែរសបាន ហា ៥ទៅ៦មឺនក្នុង១ថ្ងៃ

ក៖ ចឹងលោកពូនឹងនាក់មីងចង់ប្របកមុខរបអ្វីផ្សេងទេ?

ខ៖ អត់មានចង់តែប៉ុននឹង។

ក៖ ចាស ចុះកាលពីតូចមកលោកពូធ្លាប់ស្រមៃចង់ធ្វើអ្វីទេពេលធំឡើង?

ខ៖ បាទកាលពីតូចធ្លាប់ស្រមៃចង់ចេះធ្វើម៉ាស៊ីន។

ក៖ ចុះលោកពូបានធ្វើជាជាងម៉ាស៊ីនទេ?

ខ៖ អត់សុទ្ធ

ក៖ ចុះការងារដែរលោកពូធ្លាប់ធ្វើ តើលោកពូបានធ្វើជាអ្វី?

ខ៖ ធ្វើស្រែចំការ ដល់មានប្រពន្ធទៅណាអត់រួច។

ក៖ ស្រលាញ់ប្រពន្ធទៅណាអត់រួច ហាហាចុះដីស្រែជាដីខ្លួនឯង?

ខ៖ បាទ ដីខ្លួនឯងខ្លះនិងជួលគេខ្លះ។

ក៖ ដីស្រែប៉ុន្មានហេចត្តាដែរលោកពូដែលជាកម្មសិទ្ធិរបស់លោកពូ?

ខ៖ ដីតែកន្លះហេចត្តាទេ

ក៖ លោកពូដាំអីខ្លះ?

ខ៖ ដាំតែស្រូវ

ក៖ លោកពូដាំតែស្រូវ?

ខ៖ បាទ

ក៖ ហា

ខ៖ ដីតែកន្លះហេចប៊ិនតែធ្វើស្រូវហើយ ដល់ពេលធ្វើស្រែហើយបានទៅដាំចំការ។

ក៖ ចំការលោកពូដាំដំណាំអីគេ លោកពូដាំត្រកួន?

ខ៖ ដាំពោត

ក៖ ចាស នឹងហើយគួបផ្សំ ពេលខ្លះយើងគ្រាន់តែម៉ៅអោយគេទៅយើងក៏បានលុយដែរ។

ខ៖ នឹងហើយ

កៈ លោកពូម៉ៅបានប៉ុន្មានដែរក្នុងមួយហិចតា?

ខៈ អានឹងយើងជួលតែដីអោយគេ។

កៈ យើងជួលតែដីអោយគេ?គេគិតម៉េចអោយយើងដែរ?

ខៈ គេនឹង១០មឺនអីចឹងទៅណា

កៈ ក្នុង១ខែ?

ខៈ ក្នុង១ឆ្នាំ

កៈ ចាស ហើយលោកពូកាលនៅពីក្មេងលោកពូ
មានចំណាងចំណូលចិត្តលេងល្បែងអីខ្លះ?លោកពូនៅចាំអត់?

ខៈ នៅចាំ

កៈ ល្បែងអីខ្លះទៅ?ឮ

ខៈ ខ្ញុំអត់សូវចំណាង់ចំណូលនឹងលេងផង។ខ្ញុំនៅរៀន ពេលចេញពីរៀនមើលគោមើលអី
ជូនកាលទៅ។

កៈ ចាស ចុះពេលទំនេរៗលោកពូចូលចិត្តស្តាប់បទចម្រៀងអត់?

ខៈ ចូលចិត្ត

កៈ បទអីគេលោកពូ?

ខៈ បទ រាំវង់ រាំក្បាច់ សារ៉ាន ឡាំឡាវអីនឹងឥឡូវភ្លេចអស់ហើយ។

កៈ ហា បទចម្រៀងក្រៅពីលោកតាស៊ុន ស៊ីសាមុតលោកពូចូលចិត្តទេ?

ខៈ អោយតែចម្រៀងពីបុរាណៗចូលចិត្តទាំងអស់

កៈ លោកពូនៅតែស្តាប់ទៀតអត់?

ខៈ នៅតែស្តាប់ ចម្រៀង

កៈ ចាស ហើយលោកពូមួយថ្ងៃលោកពូស្តាប់បានប៉ុន្មានដងដែរ?

ខៈ ពេលណាអារម្មណ៍ល្អចឹងស្តាប់បានតែអារម្មណ៍មិនល្អរចឹងនៅអង្គុយ។

កៈ លោកពូចេះច្រៀងអត់?

ខៈ ភ្លេចអស់

កៈ គ្រាន់តែស្តាប់?

ខៈ តាំងពីឈឺមកខូក្បាល

កៈ ចាស ចឹងសូមអោយលោកពូឆាប់ជាឆាប់ៗនឹងមានសុខភាពល្អឡើងវិញណាលោកពូ។

ខៈ បាទ មើលទៅមិនជាដាច់ទេមើលទៅនៅតែប៉ិននឹង គ្រាន់តែបានចាំផ្ទះ។

កៈ
លោកពូចឹងដោយថាក្នុងជីវិតរបស់លោកពូឆ្លងកាត់ជីវិតនិងបទពិសោធន៍ច្រើនចឹងតើលោកពូមានបទពិសោធន៍អ្វីខ្លះដែលចង់ចែកចាយប្រាប់ ទាំងរឿងល្អនិងរឿនមិនល្អ? ឥឡូវសូមសួរលោកពូមួយចុះថាចង់ចាំរឿងអ្វីខ្លះនៅក្នុងជីវិតលោកពូ?

ខៈ កើតមកវាក្រ មើលកុនមើលល្ខោនអីមិនសូវបានទៅមើល។

កៈ លោកពូ ចូលចិត្តមើលរឿនល្ខោនកុនតែលោកពូ មិនសូវបានទៅមើលចាស ចុះបទពិសោធន៍អ្វីដែលលោកពូចង់ចាំជាងគេនៅក្នុងចិត្ត?

ខៈ បទពិសោធន៍

កៈ ចាស រឿងល្អៗដែលលោកពូបានឆ្លងកាត់មានអត់លោកពូ? ចុះរឿងដែលអត់សប្បាយចិត្តមានទេលោកពូ?

ខៈ មានមើលគេមើលឯង ខ្ញុំអត់មាន។

កៈ ចុះរឿងល្អវិញ?

ខៈ ខ្ញុំមិនដែលទៅទាស់ជាមួយបងប្អូនណាផង។

កៈ ហ៎

ខៈ បាទ បងប្អូនណារាប់អានខ្ញុំ ខ្ញុំរាប់អានជាញាតិសន្តាចឹងទៅណា

កៈ ចាស

ខៈ នឹងហើយ

កៈ
ចាសជាចុងក្រោយលោកពូមានពាក្យពេជ្យផ្តាំផ្ញើរដល់អ្នកដែលបានចូលទៅស្តាប់ក្នុងគេហទំព័រនេះទេ?

ខៈ ផ្តាំថាជីវិតខ្ញុំវាលំបាកវាមិនដូចជំនាន់ខ្ញុំវាសប្បាយ

កៈ ជាចុងក្រោយលោកពូមានពាក្យបន្ថែមទៀតទេ?

ខៈ សូមជូនពរដល់ក្មួយសុខសប្បាយ មានអាយុយឺនយូរ។

កៈ ចាស អរគុណលោកពូ
សូមអោយដូចគ្នាសូមជូនពរអោយលោកពូសុខភាពល្អអោយបានជាពីជំងឺនៅក្នុងឆ្នាំថ្មីនឹងតែម្តង និងក្រុមគ្រួសារមានសុខភមង្គល រកទទូលទានមានបាននៅក្នុងឧកាសឆ្នាំថ្មីនេះ
ហើយកូនចៅ ចៅតួត
នឹងចៅទាំងអស់សូមអោយមានសុខភាពល្អនឹងប្រកបដោយកន្លងធម៍នឹងប្រកបដោយជោគជ័យនៅក្នុងជីវិតរាងៗខ្លួន ចាស លោកពូ។
ដូច្នោះអរគុណលោកពូច្រើនដែលបានចំណាយពេល
ហើយតើលោកពូអរនុញ្ញាតអោយក្មួយយកសំលេងលោកពូទៅដាក់ក្នុងវេបសាយអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ទេលោកពូ?

ខៈ បាទ

កៈ ចឹងអរគុណច្រើនលោកពូ សូមសុខសប្បាយ។